ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**************

សាលាឧទ្ធរណ៍ភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ៣៥០ / ២៥.៥.២០១០

សាលដីកា

លេខ: ២៩ ក្រ.III.ស/២២.៣.២០១២

# តាមនាមប្រជារាស្ត្រខ្មែរ

# សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០១២ ដោយមានសមាសភាពដូចតទៅ:

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រមប្រឹក្សា

លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

ឯកឧត្តម [redacted]

**ក្រឡាបញ្ជី**

កញ្ញា [redacted]

ដើម្បីធ្វើការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ នៃសំណុំរឿងព្រហ្មទណ្ឌលេខ ៣៥០ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១០ រវាង ៖

ជនជាប់ចោទឈ្មោះ [redacted] ព្រែក ភេទប្រុស អាយុ២១ឆ្នាំ ជាតិខ្មែរ មុខរបររត់ម៉ូតូឌុប ទីលំនៅកំណើត និងទីលំនៅមុនចាប់ខ្លួន [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] មានកូន០១នាក់ ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៨ ឃុំខ្លួនថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៨ ។

មានលោក [redacted] វិបុល ជាមេធាវីការពារ ។

<u>ជាប់ចោទពីបទៈ</u> ប្លន់ ប្រព្រឹត្តនៅ ផ្ទះលេខ៨អា ផ្លូវ៣០៨ ក្រុម២៩ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោស តាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] មាណវី ភេទស្រី អាយុ៥៦ឆ្នាំ ជាតិខ្មែរ បច្ចុប្បន្នរស់នៅផ្ទះ៨អា ផ្លូវ៣០៨ ក្រុម២៩ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

**ដំណើររឿងមានដូចតទៅ ៖**

កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៨ ម៉ោងប្រហែល១៦ និង១៥នាទី មានជនល្មើសមួយក្រុម មានគ្នា ៤នាក់ មានឈ្មោះ [redacted] ព្រែក, [redacted] វាសនា, [redacted] ខ្លឹង, [redacted] ឌុល បានធ្វើសកម្មភាពលួចរួមគ្នានៅផ្ទះធ្វើបុណ្យកឋិនទានមួយ នៅចំណុចសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ដោយយកបានប្រាក់ដុល្លា ក្រវិលផ្កាទីន ៥



Scanned with CamScanner

កងដៃ ចិញ្ចៀនផ្កាកទីន ចែកគ្នាដែលបានមកពីអំពើនោះ។ លុះដល់ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៨ ឈ្មោះ [redacted] ព្រែក និង [redacted] វាសនា បានសារភាពថា បានយកចិញ្ចៀនដាំត្បូងពណ៌ទៅលក់នៅហាងផាង សិលា ស្ថិតនៅផ្ទះលេខ២៦អឺ០ ផ្លូវលេខ១៤៨ សង្កាត់ផ្សារកណ្ដាល១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៩០ ក្រ១ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅៈ

១- ផ្តន្ទាទោស

ក. ឈ្មោះ [redacted] ព្រែក ភេទប្រុស អាយុ២១ឆ្នាំ

ខ. ឈ្មោះ [redacted] វាសនា ភេទប្រុស អាយុ១៩ឆ្នាំ

ដាក់ពន្ធនាគារក្នុងម្នាក់ៗ កំណត់រយៈពេល០៧ឆ្នាំ(ប្រាំពីរឆ្នាំ) គិតពីថ្ងៃឃាត់ខ្លួន ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០ ពីបទ ប្លន់ ប្រព្រឹត្តនៅ ផ្ទះលេខ៥អា ផ្លូវ៣០៨ ក្រុម២៩ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៨ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោស តាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

២- បង្គាប់ឲ្យឈ្មោះ [redacted] ព្រែក និងឈ្មោះ [redacted] វាសនា រួមគ្នាបង់ប្រាក់សំណងសំភារៈបាត់បង់ ចំនួន ៤០.០០០.០០០រៀល (សែសិបលានរៀល) និងជម្ងឺចិត្តចំនួន ៥.០០០.០០០រៀល (ប្រាំលានរៀល) ឲ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] មាណវី, ការទាមទារលើសពីនេះត្រូវច្រានចោល។

៣- ប្រគល់កងដៃដាំត្បូងពណ៌ក្រហម, ក្រវិលពីគូដាំត្បូង ពណ៌ក្រហមមួយគូ និងពណ៌ខ្មៅមួយគូ លាយពណ៌ស រាងផ្ចិត និងប្រាក់៨៥០$ (ប្រាំបីរយហាសិបដុល្លាអាមេរិក) តាមកំណត់ហេតុប្រគល់បណ្តោះអាសន្ន ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨ របស់អធិការដ្ឋាននគរបាលខណ្ឌចំការមន ឲ្យម្ចាស់ដើមវិញ។

៤- សាលក្រមនេះ ជំនុំជម្រះ នៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៩ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៩ ចំពោះមុខជនជាប់ចោទ មេធាវីការពារជនជាប់ចោទ មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី កំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ ក្នុងកំណត់ច្បាប់។

បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ៣៧៣ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] ព្រែក ជាជនជាប់ចោទ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៩០ ក្រ១ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ គ្រប់ចំណុចទាំងមូលនៃសាលក្រម ។

បានឃើញ សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

បានឃើញ របាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍ ។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សា បញ្ជាក់អង្គហេតុរឿងជូនអង្គសវនាការ

ក្រឡាបញ្ជីអានចម្លើយជនជាប់ចោទឈ្មោះ សែម មាណវី បានឆ្លើយនៅសាលាដំបូងរាជធានីភ្នំពេញ។

ជនជាប់ចោទឈ្មោះ [redacted] ព្រែក ឆ្លើយថា ពួកខ្លួនមានគ្នា៤នាក់ មានខ្លួន [redacted] វាសន [redacted] ខ្លឹង, [redacted] ឌុល ពួកគេបានធ្វើសកម្មភាពលួចរួមគ្នានៅផ្ទះធ្វើបុណ្យកឋិនទាន នៅចំណុចសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន មែន តែខ្លួនមិនបានចូលរួមប្រព្រឹត្តទេ ខ្លួនគ្រាន់តែនៅឈរចាំម៉ូតូខាងក្រៅ ខ្លួនមិនដឹងថាពួកគេធ្វើអ្វីទេ។ ខ្លួនបានទទួលប្រាក់តែដប់ម៉ឺនរៀលប៉ុណ្ណោះ មិនមែន៨០$ ទេ។ ពេលសមត្ថកិច្ចដកហូត បាន

ក្រវិល២គូ កងដៃដាំត្បូងមួយ និងលុយបាន ៨៥០$។ សំណូមពរ សូមតុលាការបន្ធូរបន្ថយទោស និងសូមសម្រេចទៅតាមច្បាប់ ។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

បណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទធ្វើឡើងត្រឹមត្រូវតាមច្បាប់ តាមចម្លើយជនជាប់ចោទ នៅសាលាដំបូង, តាមចម្លើយរបស់ជនជាប់ចោទនៅពេលនេះ និង តាមអង្គហេតុ បញ្ជាក់ថា សកម្មភាពជនជាប់ចោទមិនមែនជាជើងក្រោយទេ សកម្មភាពនេះ ជនជាប់ចោទជាអ្នកនាំមុខ សុំសភាព្រហ្មទណ្ឌសម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៩០ ក្រ១ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញទុកជាបានការដដែល។

## សេចក្តីសន្និដ្ឋានរបស់មេធាវី

ក្នុងរឿងនេះ កូនក្តីខ្លួនគ្រាន់តែជាអ្នករត់ម៉ូតូឌុប មិនមែនជាអ្នកប្រព្រឹត្តទេ ហើយឈ្មោះ វាសនា ក៏បានបញ្ជាក់ថា កូនក្តីខ្លួនជាអ្នករត់ម៉ូតូឌុបមែន មិនបានចូលរួមក្នុងសកម្មភាពទាំងនេះទេ ហើយវាសនាបានឲ្យកូនក្តីខ្លួនចំនួន១០$ ជាថ្លៃឈ្នួលម៉ូតូប៉ុណ្ណោះ ដូចនេះបញ្ជាក់ឲ្យឃើញថា សកម្មភាពរបស់កូនក្តីខ្លួនមិនមែនជាសកម្មភាពប្លន់នោះទេ គ្រាន់តែទទួលផលចោរកម្ម សូមក្រុមប្រឹក្សាមេត្តាប្តូរបទចោទពីបទ ប្លន់ តាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ទៅជាបទទទួលផលចោរកម្ម តាមមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ និងសុំបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនដោយអនុគ្រោះ ។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទឈ្មោះ [redacted] ព្រែក,

ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] មាណវី,

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី

ក្រោយពីបានពិភាក្សា រ៉ែកញែក ល្អិតល្អន់ តាមច្បាប់

## សាលាឧទ្ធរណ៍ភ្នំពេញ

## យល់ឃើញថា:

១. បណ្តឹងឧទ្ធរណ៍លេខ ៣៧៣ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] ព្រែក ជាជនជាប់ចោទធ្វើនៅក្នុងកំណត់ច្បាប់ តាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២. ជនជាប់ចោទឆ្លើយសារភាពថា កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៨ ខ្លួន និងគូកន គឺ [redacted] វាសនា, [redacted] ខ្លឹង និង [redacted] ឌុល បាននាំគ្នាទៅលួចនៅផ្ទះលេខ៨អា ដែលកំពុងធ្វើបុណ្យកឋិន យកបានរបស់មួយចំនួន មានទាំងលុយផង បានយកទៅចែកគ្នាមែន។

ឯជនជាប់ចោទឈ្មោះ [redacted] វាសនា ក៏បានឆ្លើយសារភាពដូចគ្នាដែរ តែបានបញ្ជាក់ថា ក្នុងការធ្វើសកម្មភាពលួចនេះ មានឈ្មោះ [redacted] ឌុល និង [redacted] ខ្លឹង ជាមេគំនិត ព្រែក ជាអ្នករត់ម៉ូតូឌុប ខ្លួនយករបស់មួយចំនួនផ្ញើនឹង [redacted] ព្រែក ដោយកុហកវាថា ជារបស់អុំខ្លួន។

៣. មានពិរុទ្ធលើជនជាប់ចោទពីបទ ប្លន់ (លួចមានគូកន) ប្រព្រឹត្តនៅ ផ្ទះលេខ៨អា ផ្លូវ៣០៨ ក្រុម២៩ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៨ បទល្មើសមានចែង ៖



Scanned with CamScanner

និងឲ្យផ្តន្ទាទោស តាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ តែតាមមាត្រា ១០ នៃក្រមព្រហ្មទណ្ឌ គួរកែបទចោទទៅជាបទ លួចដោយហឹង្សា តាមមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៤. សាលក្រមព្រហ្មទណ្ឌលេខ ៩០ ក្រ១ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចត្រឹមត្រូវ គួរតម្កល់ទុកជាបានការ លើកលែងតែកម្រិតទណ្ឌកម្មនៅចំណុចទី១ លើជនជាប់ចោទឈ្មោះ ហែម ព្រែក គួរកែប្រែដូចយល់ឃើញខាងលើ។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្តី

១. ទទួលបណ្តឹងឧទ្ធរណ៍លេខ ៣៧៣ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ របស់ឈ្មោ[redacted]ព្រែក ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមច្បាប់ ។

២. តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៩០ ក្រ១ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ លើកលែងតែចំណុចទី ១ លើជនជាប់ចោទឈ្មោះ [redacted] ព្រែក ត្រូវកែប្រែៈ

ក. កែបទចោទពីបទ ប្លន់ តាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ មក ជាបទ លួចដោយហឹង្សា តាមមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ,

ខ. ផ្តន្ទាទោសលើឈ្មោះ[redacted]ព្រែក ជាតិខ្មែរ អាយុ២១ឆ្នាំ ដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ (ប្រាំឆ្នាំ) ពីបទ លួចដោយហឹង្សា តាមមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

ក្រៅពីនេះទុកនៅដដែល ។

៣. បង្គាប់ឲ្យបន្តឃុំខ្លួនជនជាប់ចោទ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០១២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០១២ ចំពោះមុខមេធាវីការពារជនជាប់ចោទ និងជនជាប់ចោទ, បើកផ្លូវសាទុក្ខតាមច្បាប់។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់ មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និង កងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។៚**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា:[redacted] | ហត្ថលេខា:[redacted], [redacted] | ហត្ថលេខា:[redacted] |

.........................................................................................................

បានឃើញ
ប្រធានសាលាឧទ្ធរណ៍

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ, ថ្ងៃទី ០៤ ខែ ០៦ ឆ្នាំ ២០១៤
ក្រឡាបញ្ជី



Scanned with CamScanner